# ថ្នាំបង្ការជម្ងឺគ្រុនផ្តាសាយធំ

## *ព័ត៌មានដែលអ្នកត្រូវដឹង*

(ថ្នាំបង្ការជម្ងឺផ្តាសាយធំ
ថ្នាំដែលមានមេរោគអសកម្ម)

**2013-2014**

Many Vaccine Information Statements are available in Spanish and other languages. See www.immunize.org/vis

មានអត្ថបទព័ត៌មានអំពីថ្នាំបង្ការជាច្រើនដែលបានបោះពុម្ពផ្សាយជាភាសាអេស្បាញ និងជាភាសាដទៃទៀត ។ សូមទស្សនាគេហទំព័រដែលមានអាសយដ្ឋាន www.immunize.org/vis

## 1 ហេតុអ្វីអ្នកត្រូវទទួលថ្នាំបង្ការជម្ងឺគ្រុនផ្តាសាយធំ?

ជម្ងឺគ្រុនផ្តាសាយធំ (“ផ្តាសាយធំ”) គឺជាជម្ងឺឆ្លង ដែលសាយភាយទូទាំងសហរដ្ឋអាមេរិក នារៀងរាល់រដូវរងារ ដលែជាធម្មតា គឺពីរវាងខែតុលា ដល់ខែឧសភា ។

ជម្ងឺផ្តាសាយធំ វាបណ្តាលមកពីមេរោគគ្រុនផ្តាសាយធំ ហើយអាចឆ្លងរាលដាលតាមការក្អក កណ្តាស់ និងការនៅ ក្បែរគ្នា ។

មនុស្សគ្រប់រូបអាចកើតជម្ងឺផ្តាសាយធំបានទាំងអស់ តែហានិភ័យនៃការកើតជម្ងឺនេះ មានភាពខ្ពស់ក្នុងចំណោមកុមារ ។ រោគសញ្ញាជម្ងឺនេះបង្ហាញឡើងភ្លាមៗពេលអ្នកឆ្លងមេរោគ ហើយវាស្ថិតនៅបី បួនថ្ងៃ  រោគសញ្ញាមានដូចជា ៖

- គ្រុនក្តៅ/គ្រុនញាក់
- ឈឺបំពង់ក
- ឈឺសាច់ដុំ
- ល្ហិតល្ហៃ
- ក្អក
- ឈឺក្បាល
- ហៀរសំបោរ ឬតឹងច្រមុះ

ជម្ងឺផ្តាសាយធំ នេះ វាអាចធ្វើឲ្យមនុស្សខ្លះឈឺខ្លាំងជាងអ្នកដទៃ ។ អ្នកទាំងនោះមានដូចជា កុមារតូចៗ មនុស្សចាស់មានអាយុ 65 ឆ្នាំ ឬចាស់ជាងនេះ ស្ត្រីមានផ្ទៃពោះ និងអ្នកដែលមានស្ថានភាពសុខភាពមិនមាំមួនណាមួយដូចជា—ជម្ងឺបេះដូង សួត និងតម្រងនោម ឬអ្នកដែលមានប្រព័ន្ធភាពស៊ាំនឹងជម្ងឺខ្សោយ ។ ថ្នាំបង្ការជម្ងឺផ្តាសាយធំ មានសារៈសំខាន់ពិសេសសម្រាប់អ្នកទាំងអស់នេះ និងអ្នកដទៃដែលស្ថិតនៅជិតអ្នកទាំងនេះ ។

ជម្ងឺផ្តាសាយធំនេះក៏អាចនាំឲ្យកើតជម្ងឺរលាកសួត និងធ្វើឲ្យស្ថានភាពជម្ងឺចាស់កាន់តែធ្ងន់ធ្ងរឡើង ។ ចំពោះកុមារវាអាចបណ្តាលក្អែងរាគ និងប្រកាច់ ។

ក្នុងមួយឆ្នាំមាន**មនុស្សរាប់ពាន់នាក់នៅសហរដ្ឋអាមេរិកស្លាប់បាត់បង់ជីវិតដោយសារជម្ងឺផ្តាសាយធំ** និងមួយចំនួនធំទៀតត្រូវចូលសម្រាកពេទ្យ ។

**ថ្នាំបង្ការជម្ងឺ ផ្តាសាយធំ** គឺជាការការពារដ៏ប្រសើរបំផុត ដែលយើងមានសម្រាប់ការពារជម្ងឺនេះ និងជម្ងឺដទៃដែលកើតឡើងដោយសារអ្នកឆ្លងជម្ងឺនេះ ។ ថ្នាំបង្ការជម្ងឺ ផ្តាសាយធំក៏អាចជួយការពារមិនឲ្យជម្ងឺនេះឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតផងដែរ ។

## 2 ថ្នាំបង្ការជម្ងឺ ផ្តាសាយធំ មេរោគអសកម្ម

ថ្នាំបង្ការជម្ងឺគ្រុនផ្តាសាយធំ មានពីរប្រភេទ ៖

អ្នកត្រូវទទួលថ្នាំបង្ការជម្ងឺផ្តាសាយធំមេរោគ**អសកម្ម**ដែលមិនមានរួមផ្សំដោយមេរោគដែលនៅមានជីវិតរបស់ជម្ងឺគ្រុនផ្តាសាយធំឡើយ ។ ថ្នាំបង្ការប្រភេទនេះត្រូវផ្តល់ឲ្យការចាក់ចូលក្នុងសាច់ដុំដោយម្ជុល ហើយដែលជាញយៗ ត្រូវបានគេហៅថា “ការចាក់ថ្នាំបង្ការជម្ងឺផ្តាសាយធំ” ។

ថ្នាំបង្ការជម្ងឺគ្រុនផ្តាសាយធំមួយប្រភេទទៀតដែល**មានបញ្ចូលមេរោគផ្តាសាយធំនៅរស់តែខ្សោយ** (មេរោគដែលមានកម្លាំងខ្សោយ) ត្រូវប្រើដោយការបាញ់បញ្ចូលតាមរន្ធច្រមុះ *។ បង្ការប្រភេទនេះ ត្រូវបានរៀបរាប់បង្ហាញដោយអត្ថបទព័ត៌មានអំពីថ្នាំបង្ការដាច់ដោយឡែកមួយទៀត ។*

គ្រូពេទ្យសូមណែនាំឲ្យអ្នកត្រូវទទួលថ្នាំបង្ការជម្ងឺផ្តាសាយធំជារៀងរាល់ឆ្នាំ ។ ចំពោះកុមារដែលមានអាយុចាប់ពី 6 ខែ ដល់ 8 ឆ្នាំ គួរបានទទួលថ្នាំបង្ការប្រភេទនេះ ចំនួនពីរកម្រិតថ្នាំដែលត្រូវប្រើ នៅ ក្នុងឆ្នាំដំបូងដែលពួកគេទើបទទួលថ្នាំបង្ការជម្ងឺនេះជាលើកដំបូង ។

ជានិច្ចកាល ថ្នាំបង្ការជម្ងឺ ផ្តាសាយធំ តែងតែមានការផ្លាស់ប្តូរ ។ ក្នុងឆ្នាំនីមួយៗ ថ្នាំបង្ការជម្ងឺ ផ្តាសាយធំត្រូវបានផលិតដើម្បីការពារចំពោះមេរោគប្រភេទដែលអាចនឹងបង្កឲ្យកើតជម្ងឺនេះក្នុងឆ្នាំនោះ ។  ដូចយើងបានដឹងហើយថា ថ្នាំបង្ការជម្ងឺ ផ្តាសាយធំ វាមិនអាចបង្ការមិនឲ្យកើតជម្ងឺ ផ្តាសាយធំបានគ្រប់ករណីឡើយ តែអ្វីដែលយើងធ្វើគឺជាវិធីការពារដ៏ប្រសើរបំផុតរបស់យើងប្រឆាំងនឹងជម្ងឺនេះ ។ ថ្នាំបង្ការជម្ងឺផ្តាសាយធំដែលមានមេរោគអសកម្មមានប្រសិទ្ធិភាពប្រឆាំងនឹងមេរោគគ្រុនផ្តាសាយធំចំនួន 3 ឬ 4 ប្រភេទ ផ្សេងៗគ្នា ។

ថ្នាំបង្ការប្រភេទនេះត្រូវប្រើពេលចំនួនប្រហែលជា 2សប្តាហ៍ក្រោយការទទួលដើម្បីអាចបង្កើតរបាំងការពារមេរោគបាន ហើយរបាំងការពារនេះនឹងស្ថិតនៅមានប្រសិទ្ធិភាពចំនួនបីបួនខែ ទៅមួយឆ្នាំ ។

ជម្ងឺមួយចំនួនដែលមិនមែនបណ្តាលមកពីមេរោគគ្រុនផ្តាសាយធំ ជាញយៗត្រូវបានគេយល់ច្រឡំថាគឺជា ជម្ងឺផ្តាសាយធំបណ្តាលមកពីមេរោគនៃជម្ងឺនេះ ។ ថ្នាំបង្ការជម្ងឺ ផ្តាសាយធំ នឹងមិនអាចការពារមិនឲ្យជម្ងឺទាំងនេះកើតឡើងបានឡើយ ។ ថ្នាំបង្ការប្រភេទនេះ អាចការពារបានតែជម្ងឺគ្រុនផ្តាសាយធំតែប៉ុណ្ណោះទេ។

ថ្នាំបង្ការជម្ងឺផ្តាសាយធំ “ក្នុងកម្រិតប្រើប្រាស់ខ្ពស់” មានឲ្យប្រើប្រាស់សម្រាប់មនុស្សចាស់ដែលមានអាយុចាប់ពី 65 ឆ្នាំ ឬចាស់ជាងនេះ ។ អ្នកដែលផ្តល់ថ្នាំបង្ការឲ្យអ្នក អាចផ្តល់ឲ្យអ្នកនូវព័ត៌មានបន្ថែមទៀត ។

ប្រភេទខ្លះនៃថ្នាំបង្ការជម្ងឺផ្តាសាយធំដែលមានមេរោគអសកម្ម មានផ្សំទៅដោយសារធាតុបារ៉តដើម្បីការពារភាពផ្អូម ដែលហៅថាក្នុងបរិមាណដ៏តិចតួចមួយដែលហៅថាសារធាតុធីមេរ៉ូសាល(សារធាតុផ្សះ នឹងប្រឆាំងមេរោគផ្សិត) ។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញឲ្យឃើញថា សារធាតុធីមេរ៉ូសាលដែលមានលាយនៅក្នុងថ្នាំបង្ការ មិនបណ្តាលឲ្យមានគ្រោះថ្នាក់អ្វីឡើយ តែបើអ្នកមិនទុកចិត្តចំពោះសុវត្ថិភាពនៃថ្នាំបង្ការប្រភេទនេះទេ អ្នកអាចជ្រើសរើសប្រើថ្នាំបង្ការជម្ងឺនេះ ប្រភេទផ្សេងបាន ។

## 3 ប្រភេទមនុស្សដែលមិនអាចទទួលថ្នាំបង្ការប្រភេទនេះបាន

ចូរប្រាប់គ្រូពេទ្យដែលជាអ្នកផ្តល់ ថ្នាំបង្ការឲ្យអ្នកបានដឹង ៖

- **ប្រសិនបើអ្នកមានប្រតិកម្មធាតុធ្ងន់ធ្ងរ** (**គ្រោះថ្នាក់ដល់ជីវិត**) **។** ប្រសិនបើអ្នកធ្លាប់មានប្រតិកម្មធាតុធ្ងន់ធ្ងរដែលអាចគ្រោះថ្នាក់ដល់ជីវិត ក្រោយពេលអ្នកបានទទួលមួយកម្រិតប្រើនៃថ្នាំបង្ការជម្ងឺ ផ្តាសាយធំ ឬមានប្រតិកម្មធ្ងន់ធ្ងរទៅនឹងផ្នែកណាមួយនៃថ្នាំបង្ការនេះ អ្នកមិនត្រូវប្រើថ្នាំបង្ការប្រភេទនេះទៀតឡើយ ភាគច្រើន តែមិនទាំងអស់នោះទេ នៃប្រភេទថ្នាំបង្ការជម្ងឺផ្តាសាយធំមានលាយទៅដោយសារធាតុនៅក្នុងស៊ុតមាន់ក្នុងបរិមាណតិចតួចមួយ ។
- **បើអ្នកធ្លាប់មានប្រជុំរោគសញ្ញាជម្ងឺប្រព័ន្ធសរសៃប្រសាទធ្ងន់ធ្ងរ** (Guillain-Barré Syndrome) (ជម្ងឺធ្វើឲ្យពិការរាងកាយ ឬដែលគេហៅផងដែរថា GBS) ។ មនុស្សខ្លះដែលធ្លាប់មានប្រវត្តិកើតជម្ងឺនេះ មិនគួរប្រើថ្នាំបង្ការនេះទេ ។ ប្រការនេះត្រូវពិភាក្សាជាមួយគ្រូពេទ្យរបស់អ្នក។
- **ប្រសិនបើអ្នកមិនស្រួលក្នុងខ្លួន ។** គ្រូពេទ្យអាចណែនាំឲ្យអ្នករង់ចាំសិន ។ តែក្រោយពីនេះអ្នកត្រូវត្រឡប់មកជួបគ្រូពេទ្យវិញ ។

U.S. Department of
Health and Human Services
Centers for Disease
Control and Prevention

## 4 ហានិភ័យបណ្ដាលពីប្រតិកម្មថ្នាំបង្ការ

ថ្នាំបង្ការ ក៏ដូចជាថ្នាំដទៃទៀតដែរ គឺតែងតែអាចកើតមានផលប៉ះពាល់ ។ ផលប៉ះពាល់ទាំងនេះ ជាធម្មតាមិនធ្ងន់ធ្ងរ ហើយនឹងបាត់ទៅវិញដោយខ្លួនឯង ។

ផលប៉ះពាល់ធ្ងន់ធ្ងរ ក៏អាចកើតឡើងបានដែរ តែជាករណីមួយដែលកម្រកើតមានណាស់ ។ ថ្នាំបង្ការជម្ងឺផ្ដាសាយធំមានមេរោគអសកម្មជាថ្នាំបង្ការដែលមិនមានបញ្ចូលមេរោគផ្ដាសាយធំនៅមានជីវិតឡើយ ដូច្នេះ **ការដែលគិតថាអ្នកអាចកើតជម្ងឺផ្ដាសាយធំបណ្ដាលពីការចាក់ថ្នាំបង្ការប្រភេទនេះ គឺជារឿងមួយដែលមិនអាចកើតឡើងបានឡើយ ។**

ខ្សោយចង់សន្លប់ក្នុងរយៈពេលខ្លី និងរោគសញ្ញាផ្សេងៗទៀតដែលពាក់ព័ន្ធ ( ដូចជាចលនាញ៉ោច ឬកន្ត្រាក់ ) អាចកើតឡើងបានក្រោយពីទទួលការធ្វើទម្រង់ការវេជ្ជសាស្ត្រណាមួយ ដោយរួមទាំងការចាក់ ឬបន្តក់ថ្នាំបង្ការជម្ងឺផងដែរ ។ **ការអង្គុយចុះ ឬទម្រេតខ្លួនដេកប្រហែលជា 15 នាទី ក្រោយការចាក់ ឬបន្តក់ថ្នាំបង្ការអាចជួយការពារពីការខ្សោយចង់សន្លប់ និងការរងរបួសស្នាមបណ្ដាលពី ការដួល ។** សូមប្រាប់ឲ្យគ្រូពេទ្យរបស់អ្នកអោយបានដឹង ប្រសិនបើបើអ្នកមានអារម្មណ៍វិលមុខ ឬឈឺក្បាលតិចៗ ឬមើលឃើញអ្វីខុសប្រក្រតី ឬហ៊ឹងត្រចៀក ។

**ផលប៉ះពាល់ក្នុងកម្រិតស្រាល** បន្ទាប់ពីបានទទួលថ្នាំបង្ការជម្ងឺផ្ដាសាយធំមានមេរោគអសកម្ម ៖

- ឈឺ ឡើងក្រហម ឬហើម ត្រង់បរិវេណចាក់ម្ជុលចូលក្នុងសាច់
- ភាពស្អកស្អាក ភ្នែកឈឺ ឡើងក្រហម ឬរមាស់ ក្អក
- គ្រុនក្ដៅ
- ឈឺចាប់លើរាងកាយ
- ឈឺក្បាល
- រមាស់លើស្បែក
- ល្ហិតល្ហៃ

បើមានប្រតិកម្មកើតឡើង ជាធម្មតាវានឹងកើតឡើងភ្លាមៗបន្ទាប់ពីការចាក់ ហើយវានឹងស្ថិតនៅ 1 ឬ 2 ថ្ងៃ ។

**ផលប៉ះពាល់ក្នុងកម្រិតមធ្យម** បន្ទាប់ពីបានទទួលថ្នាំបង្ការជម្ងឺផ្ដាសាយធំមានមេរោគអសកម្ម ៖

- ចំពោះកុមារតូចដែលទទួលការចាក់ថ្នាំបង្ការជម្ងឺផ្ដាសាយធំ និងថ្នាំបង្ការជម្ងឺរលាកសួត (PCV13) ក្នុងពេលតែមួយ អាចបង្កឲ្យមានហានិភ័យខ្ពស់ចំពោះភាពប្រកាច់ បណ្ដាលពីគ្រុនក្ដៅ ។ សូមសួរគ្រូពេទ្យរបស់អ្នកដើម្បីបានទទួលព័ត៌មានបន្ថែម ។ សូមប្រាប់ឲ្យគ្រូពេទ្យអោយបានដឹងផងប្រសិនបើកុមារដែលនឹងចាក់ថ្នាំបង្ការជម្ងឺផ្ដាសាយធំ ធ្លាប់ប្រកាច់កាលពីពេលមុន ។

**ផលប៉ះពាល់ក្នុងកម្រិតធ្ងន់ធ្ងរ** បន្ទាប់ពីបានទទួលថ្នាំបង្ការផ្ដាសាយធំមានមេរោគអសកម្ម ៖

- **ប្រតិកម្មធាតុធ្ងន់ធ្ងរ**អាចកើតមាន ក្រោយពេលទទួលថ្នាំបង្ការប្រភេទណាមួយរួច ( ការប៉ាន់ស្មានគឺថាប្រតិកម្មកម្រិតធ្ងន់បែបនេះអាចកើតមានតិចជាង 1 ដងក្នុងមួយលានកម្រិតប្រើ ) ។
- មានភាពដែលអាចកើតឡើងបានក្នុងកម្រិតទាបចំពោះលទ្ធភាពដែលថាថ្នាំបង្ការជម្ងឺផ្ដាសាយធំដែលមានមេរោគអសកម្ម អាចមានបណ្ដុំរោគសញ្ញាជម្ងឺប្រព័ន្ធសរសៃប្រសាទធ្ងន់ធ្ងរ (GBS) គឺមិនមានកើតឡើងច្រើនជាង 1 ឬ 2 ករណីឡើយ ក្នុងមនុស្សមួយលាននាក់ដែលបានចាក់ថ្នាំបង្ការនេះ ។ ប្រតិកម្មប្រភេទនេះ គឺមានកម្រិតទាបឆ្ងាយជាងផលវិបាកធ្ងន់ធ្ងរដែលបង្កឡើងដោយជម្ងឺផ្ដាសាយធំ ដែលអាចការពារបានដោយការចាក់ថ្នាំបង្ការជម្ងឺផ្ដាសាយធំ ។

សុវត្ថិភាពនៃថ្នាំបង្ការ ជានិច្ចកាលតែងបានទទួលការត្រួតពិនិត្យ ។ សម្រាប់ព័ត៌មានបន្ថែមសូមទស្សនា គេហទំព័រ ៖ **www.cdc.gov/vaccinesafety/**

## 5 តើត្រូវធ្វើដូចម្ដេចបើប្រតិកម្មធ្ងន់ធ្ងរកើតឡើង?

### តើខ្ញុំត្រូវរកមើលអ្វី?

- ត្រូវរកមើលអ្វីដែលធ្វើឲ្យអ្នកបារម្ភ ដូចជាសញ្ញានានាអំពីប្រតិកម្មធ្ងន់ធ្ងរ គ្រុនក្ដៅខ្លាំង ឬការប្រែប្រួលអាកប្បកិរិយារបស់អ្នកជម្ងឺ ។

  សញ្ញានានាអំពីប្រតិកម្មក្នុងកម្រិតធ្ងន់ធ្ងរអាចមានរួមបញ្ចូលនូវការឡើងបន្ទាលត្រអាក ហើមមុខ និងបំពង់ក ពិបាកដកដង្ហើម បេះដូងដើរញាប់ វិលមុខ និងខ្សោយកម្លាំង ។ សញ្ញាទាំងនេះ អាចកើតឡើងពីរបីនាទី ទៅពីរបីម៉ោង ក្រោយពីការទទួលថ្នាំបង្ការរួច ។

### តើខ្ញុំត្រូវធ្វើអ្វីខ្លះ?

- បើអ្នកគិតថាវាគឺជាប្រតិកម្មក្នុងកម្រិតធ្ងន់ធ្ងរ ឬជាភាពអាសន្នដទៃទៀតដែលអ្នកមិនអាចរង់ចាំបាន សូមហៅទូរស័ព្ទទៅកាន់លេខ 9-1-1 ឬយកអ្នកជម្ងឺទៅកាន់មន្ទីរពេទ្យដែលនៅក្បែរលោកអ្នកជាទីបំផុត ។ បើមិនដូច្នេះទេ សូមហៅទូរស័ព្ទទៅជួបគ្រូពេទ្យរបស់អ្នក ។ x
- បន្ទាប់មក អ្នកត្រូវរាយការណ៍អំពីប្រតិកម្មនេះ ទៅកាន់ ប្រព័ន្ធរាយការណ៍ហេតុការណ៍ប្រតិកម្មថ្នាំបង្ការជម្ងឺ (Vaccine Adverse Event Reporting System -VAERS) ។ គ្រូពេទ្យរបស់អ្នក អាចរាយការណ៍អំពីបញ្ហានេះ ឬអ្នកអាចរាយការណ៍ដោយខ្លួនឯង តាមរយៈគេហទំព័ររបស់ VAERS ដែលមានអាសយដ្ឋាន **www.vaers.hhs.go**v ឬដោយការហៅទូរស័ព្ទទៅកាន់លេខ **1-800-822-7967** ។

*VAERS គឺគ្រាន់តែជាកន្លែងសម្រាប់រាយការណ៍អំពីប្រតិកម្មថ្នាំតែប៉ុណ្ណោះ ។ ពួកគេមិនមែនជាអ្នកផ្ដល់ដំបូន្មានវេជ្ជសាស្ត្រដល់អ្នកឡើយ ។*

## 6 កម្មវិធីជាតិផ្ដល់សំណងចំពោះរបួសស្នាមបណ្ដាលពីថ្នាំបង្ការ

កម្មវិធីជាតិផ្ដល់សំណងចំពោះរបួសស្នាមបណ្ដាលពីថ្នាំបង្ការ (National Vaccine Injury Compensation Program -VICP) គឺជាកម្មវិធីរបស់រដ្ឋាភិបាលសហព័ន្ធ ដែលត្រូវបានបង្កើតឡើងសម្រាប់ផ្ដល់សំណងដល់ពលរដ្ឋដែលអាចរងរបួស បណ្ដាលពីថ្នាំបង្ការណាមួយ ។

ចំពោះអ្នកណាដែលមានជំនឿថាខ្លួនបានរងរបួសបណ្ដាលមកពីថ្នាំបង្ការជម្ងឺ អាចសិក្សាអំពីកម្មវិធីនេះ និងវិធីដាក់ពាក្យទាមទារសំណង ដោយការ ហៅទូរស័ព្ទមកកាន់លេខ **1-800-338-2382** ឬទស្សនាគេហទំព័ររបស់ VICP ដែលមានអាសយដ្ឋាន **www.hrsa.gov/vaccinecompensation** ។

## 7 តើខ្ញុំអាចបានដឹងព័ត៌មានអំពីថ្នាំបង្ការជម្ងឺដោយវិធីណា?

- សូមសួរគ្រូពេទ្យរបស់អ្នក ។
- ហៅទូរស័ព្ទមកកាន់នាយកដ្ឋានសុខាភិបាលប្រចាំមូលដ្ឋាន ឬប្រចាំរដ្ឋរបស់អ្នក ។
- ទំនាក់ទំនងជាមួយនឹងមជ្ឈ មណ្ឌលគ្រប់គ្រង និងការពារជម្ងឺ
  - ហៅទូរស័ព្ទមកកាន់លេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ទស្សនាគេហទំព័ររបស់ CDC ដែលមានអាសយដ្ឋាន **www.cdc.gov/flu**


Vaccine Information Statement (Interim)

Inactivated Influenza Vaccine

Cambodian

07/26/2013

42 U.S.C. § 300aa-26

Office Use Only

Translation provided by the California Department of Public Health